YUNNAN DAILY PRESS GROUP
云南日报报业集团
No.117

# ប្រទេសចិន-ខេត្តយូនណាន

ស្មៀតកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7387 ថ្ងៃសុក្រ ទី21 ខែកក្កដា ឆ្នាំ 2017

## សិក្ខាសាលា "ប្រទេសចិនដ៏ស្រស់ស្អាត" ជំរុញកិច្ចសហប្រតិបត្តិការចិន-កម្ពុជា

*ប្រទេសចិនមានជនជាតិ ៥៦ក្រុម ហើយក្រុមជនភាគតិច ទាំងនេះមានវប្បធម៌និងបង្កើតភាព ស្រស់ស្អាតដល់ចិនដ៏ចម្រុះ ។ ដោយឡែកនេះគឺជារាំលេងសក់ម្យ៉ាងរបស់ ប្រជាពលរដ្ឋនៅភាគនិរតីនៃខេត្ត យូនណាន ប្រទេសចិន*
*(រូបថត ដោយ Ding Shurong )*

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ គណៈប្រតិភូទេសចរចិនបានរៀបចំសិក្ខាសាលា"ប្រទេសចិនដ៏ស្រស់ស្អាត" នៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្សព្វផ្សាយអំពីផលិតផលទេសចរណ៍ចិនជូនចំពោះប្រជាជនខ្មែរ។

តំណាងនៃក្រុមហ៊ុនទេសចរណ៍ក្រុមហ៊ុនអាកាសចរណ៍ និងប្រព័ន្ធផ្សព្វផ្សាយ បានចូលរួមក្នុងសិក្ខាសាលានេះ ។ អ្នកប្រកបអាជីពទេសចរណ៍ដែលមកពីខេត្ត ចំនួន១០នៃប្រទេសចិនបានធ្វើបទបង្ហាញ អំពីលក្ខណៈពិសេសនៃតំបន់ទេសចរណ៍ផ្សេងៗក្នុងឱកាសសិក្ខាសាលានេះ ។

លោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍កម្ពុជាមានប្រសាសន៍ថា យុទ្ធសាស្ត្រ "ខ្សែក្រវ៉ាត់មួយ និងផ្លូវមួយ" នឹងជំរុញការអភិវឌ្ឍនៃវិស័យទេសចរណ៍របស់ប្រទេសកម្ពុជា និងបណ្តាប្រទេសនានាតាមបណ្តោយ "ខ្សែក្រវ៉ាត់មួយនិងផ្លូវមួយ" ។ លោកសង្ឃឹមថាក្រសួងទេសចរណ៍កម្ពុជានិងអាជ្ញាធរជាតិទេសចរណ៍ចិននឹងអាចពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស្និតល្អត ។

គួរបញ្ជាក់ថា ក្នុងអំឡុងពេលពីខែមករាដល់ ខែឧសភា ឆ្នាំ២០១៧ កម្ពុជាបានទទួលទេសចរចិនប្រមាណ៤៤ម៉ឺននាក់កើនឡើងជាង៣០ភាគរយធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១៦ ។ ប្រទេសចិនបានក្លាយជាប្រភពទេសចរធំជាងគេរបស់ប្រទេសកម្ពុជា ។ មិនតែប៉ុណ្ណោះទន្ទឹមនឹងការអភិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជាមានប្រជាជនខ្មែរកាន់តែច្រើននឹងទៅធ្វើទេសចរនៅប្រទេសចិន និងប្រទេសផ្សេងៗទៀតលើពិភពលោក ។

## មជ្ឈមណ្ឌលភាសាចិននៃក្រសួងការពារជាតិកម្ពុជាសម្ពោធជាផ្លូវការ

មជ្ឈមណ្ឌលភាសាចិននៃក្រសួងការពារជាតិកម្ពុជា ដែលបង្កើតដោយវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជាបានត្រូវដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនៅរាជធានីភ្នំពេញ ។

លោកនាយឧត្តមសេនីយ៍ ផ្យេង អំ រដ្ឋលេខាធិការនៃក្រសួងការពារជាតិកម្ពុជាបានថ្លែងសុន្ទរកថាក្នុងពិធីសម្ពោធនេះ ។ លោកបានថ្លែងអំណរគុណចំពោះវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលបានបង្កើតមជ្ឈមណ្ឌលភាសាចិននៅក្រសួងការពារជាតិកម្ពុជា ដើម្បីជួយបណ្តុះបណ្តាលទាហានខ្មែរឱ្យចេះនិយាយភាសាចិន ។ លោកបានលើកសំណូមពរឱ្យសិក្ខាកាមគ្រប់រូបខិតខំរៀនភាសាចិនឱ្យបានល្អ ដើម្បីរួមចំណែកក្នុងការពង្រឹងចំណងមិត្តភាពនិងបង្កើនការផ្លាស់ប្តូររវាងកងទ័ពនៃប្រទេសទាំងពីរកម្ពុជា និងចិន ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា មជ្ឈមណ្ឌលភាសាចិននេះ បានជ្រើសរើសសិក្ខាកាម៦០នាក់ឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលទី១ ដែលនឹងផ្តល់ការអប់រំផ្នែកភាសាចិនពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ។ គួរបញ្ជាក់ថា វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជាបានបង្កើតថ្នាក់បង្រៀនភាសាចិនច្រើនក្នុងស្ថាប័នយោធាកម្ពុជា រួមមានសាលាយោធាទ័ពលោតឆត្រ និងមន្ទីរពេទ្យយោធាជាដើម ។

**(អត្ថបទពីទីភ្នាក់ងារព័ត៌មានស៊ីនហ្វូចិន)**
**ផ្នែកផលិតកម្មយូនណាន**

## ព្រលានយន្តហោះអន្តរជាតិ ឆាងសួយ ក្រុងគុនមីងបង្កើនជើងហោះហើរទៅប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍

***ដោយ ហ្ស៊ង ដឺឈុន***

តាំងពីដើមឆ្នាំនេះមក ជើងហោះហើរអន្តរជាតិនៃព្រលានយន្តហោះអន្តរជាតិឆាងសួយ ក្រុងគុនមីងបានកើនឡើងក្នុងល្បឿនយ៉ាងលឿនជាពិសេសជើងហោះហើរទៅកាន់ប្រទេសអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍។

គិតមកដល់ខែឧសភាឆ្នាំនេះ ព្រលានយន្តហោះអន្តរជាតិឆាងសួយ ក្រុងគុនមីងបានបង្កើតខ្សែផ្លូវអាកាសចរណ៍ចំនួន៥២ ដែលហោះហើរទៅកាន់ប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។ ក្នុងនោះមាន៤១ខ្សែហោះហើរទៅកាន់ប្រទេសអាស៊ីអាគ្នេយ៍ និងមាន១១ខ្សែហោះហើរទៅកាន់ប្រទេសអាស៊ីខាងត្បូង ។ ក្រៅពីនេះខ្សែផ្លូវអាកាសចរណ៍អន្តរជាតិសម្រាប់ដឹកទំនិញ ក៏បានទទួលការរីកចម្រើនគួរជាទីកត់សម្គាល់ដែរ ដែលបានជំរុញការអភិវឌ្ឍន៍នៃព្រលានយន្តហោះអន្តរជាតិឆាងសួយក្រុងគុនមីង។ នៅខែកក្កដា ជើងហោះហើរពីក្រុងគុនមីងទៅប្រទេសអាស៊ីអាគ្នេយ៍នឹងកើនឡើងដល់ទៅ១៨៨ជើងក្នុងមួយសប្តាហ៍ ចំណែកជើងហោះហើរទៅប្រទេសអាស៊ីខាងត្បូងនឹងអាចកើនឡើងដល់ទៅ៣៦ជើងក្នុងមួយសប្តាហ៍ ដែលបានបង្ហាញពីនិន្នាការអភិវឌ្ឍន៍គួរឱ្យកត់សម្គាល់ ។ រូបថតនេះបានបង្ហាញពីទិដ្ឋភាព ដែលអ្នកដំណើរចុះពីលើជើងហោះហើរអន្តរជាតិនៅព្រលានយន្តហោះក្រុងគុនមីង។

ក្នុងអំឡុងពេលពីខែមករាដល់ខែមិថុនា ឆ្នាំ២០១៧ យន្តហោះដែលហោះហើរ និងចុះចតនៅព្រលានយន្តហោះក្រុងគុនមីងមាន២៤,៨ម៉ឺនគ្រឿង កើនឡើង៨,២ភាគរយ ហើយមានអ្នកដំណើរ៣១.០២៦លាននាក់កើនឡើង១០ភាគរយ និងបានដឹកជញ្ជូនទំនិញ២១,៤ម៉ឺនតោន កើនឡើង ៩,៨ភាគរយ ។

## អគ្គិសនីរបស់យូនណាននឹងបំភ្លឺភ្លើងកាន់តែច្រើន

***ដោយ ហាន លីងយាន់***

*គម្រោងកសាងខ្សែបណ្តាញ អគ្គិសនីតង់ស្យុងខ្ពស់នៅខេត្តយូនណាន*
*(រូបថត ដោយ Zhu Bing )*

ខេត្តយូនណានជាច្រកដ៏សំខាន់លើដីគោកសម្រាប់តភ្ជាប់ប្រទេសចិនជាមួយប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។ ១០ឆ្នាំមុន ខេត្តយូនណានបានបញ្ជូនថាមពលអគ្គិសនីទៅដល់ប្រទេសជិតខាងច្រើន តាមរយៈបច្ចេកទេសបញ្ជូនអគ្គិសនីដោយប្រើប្រាស់សម្ពាធខ្ពស់ ចម្ងាយឆ្ងាយ និងទំហំធំ ។ គិតមកដល់ពេលនេះ ខេត្តយូនណានបានតភ្ជាប់បណ្តាញបញ្ជូនអគ្គិសនីទៅនឹងប្រទេសវៀតណាម ឡាវ និងមីយ៉ាន់ម៉ា តាមរយៈខ្សែបញ្ជូនអគ្គិសនីសម្ពាធខ្ពស់ ។

ក្រុមហ៊ុនសាងសង់បណ្តាញអគ្គិសនីភាគខាងត្បូងចិន ជាអ្នកអនុវត្តន៍ដ៏សំខាន់ក្នុងដំណើរអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីចិន ។ គិតមកដល់ចុងឆ្នាំ២០១៦ ក្រុមហ៊ុននេះបានធ្វើពាណិជ្ជកម្មថាមពលអគ្គិសនីជាមួយប្រទេសវៀតណាម ឡាវ និងមីយ៉ាន់ម៉ា ដែលមានទំហំសរុប៤៨.៥០០លានគីឡូវ៉ាត់មួយម៉ោង ។

លោក ចូវ ជីន អគ្គនាយកនៃក្រុមហ៊ុនវារីអគ្គិសនីផ្នែកខាងលើទន្លេឡានអាង ហ្គូនីង បានឧទ្ទេសនាមថាស្ថានីយវារីអគ្គិសនីថ្នាក់ ១ ទន្លេយ្ងយលីដែលសាងសង់ដោយក្រុមហ៊ុនយើងខ្ញុំនោះ ស្ថិតនៅក្បែរភូមិប៉ានតានៃប្រទេសមីយ៉ាន់ម៉ា ។ ក្នុងភូមិនេះមានអ្នកភូមិ ៨២០នាក់ ដែលគ្មានភ្លើងអគ្គិសនីប្រើប្រាស់ជាយូរមកហើយ ។ នៅឆ្នាំ ២០១២ ក្រុមហ៊ុនយើងខ្ញុំបានបញ្ជូនអគ្គិសនីទៅក្នុងភូមិនេះ ដែលបានធ្វើឱ្យគ្រប់ក្រុមគ្រួសារក្នុងភូមិនេះអាចប្រើប្រាស់ថាមពលអគ្គិសនីបាន ។

លោក ស្យ៊ អ៊ែមីន អ្នកទទួលខុសត្រូវចំពោះការកំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងការពង្រីកកិច្ចការតាមទីផ្សារអន្តរជាតិនៃក្រុមហ៊ុនបច្ចេកវិជ្ជា PV ឡឺយី ឡុងជី បានគូសបញ្ជាក់ថា នៅឆ្នាំ ២០១៦ យើងខ្ញុំចាប់ផ្តើមដាក់ទុនវិនិយោគទំហំធំនៅខេត្តយូនណានដើម្បីអភិវឌ្ឍន៍ប្រព័ន្ធផលិតអគ្គិសនីដោយប្រើប្រាស់បច្ចេកទេស PV ។ យើងខ្ញុំក៏បានទៅពង្រីកកិច្ចការនៅទីផ្សារម៉ាឡេស៊ីដែរ ហើយសង្ឃឹមថានឹងអាចជំរុញការអភិវឌ្ឍវិស័យវារីអគ្គិសនីអាស្រ័យលើឧត្តមភាពវារីអគ្គិសនីរបស់ខេត្តយូនណាននិងប្រទេសអាស៊ីអាគ្នេយ៍ ហើយបង្កើតជាប្រព័ន្ធផ្គត់ផ្គង់ថាមពលអគ្គិសនីចម្រុះមួយ ដែលច្រកចាច់បញ្ចូលគ្នានូវអគ្គិសនី PV វារីអគ្គិសនី និងអគ្គិសនីដើរដោយកម្លាំងខ្យល់ ។

នាពេលអនាគត ខេត្តយូនណានមិនគ្រាន់តែអាចជំរុញការតភ្ជាប់បណ្តាញបញ្ជូនអគ្គិសនីប៉ុណ្ណោះទេ ហើយនឹងអាចទទួលសមិទ្ធផលកាន់តែច្រើនក្នុងការអភិវឌ្ឍផលិតផលថាមពលដែលអាចប្រើប្រាស់ជាថ្មីឡើងវិញ ។ ឈរលើជំហរនិងគោលការណ៍ដែលរួមគ្នាពិគ្រោះពិភាក្សា ស្តាបនា និងចែករំលែកគ្នា ខេត្តយូនណាននឹងអាចបំភ្លឺភ្លើងកាន់តែច្រើនក្នុងទីក្រុង ឬតំបន់ជនបទនៃបណ្តាប្រទេសជិតខាងនានា។

## យន្តហោះធុនស្រាលរបស់ខេត្តយូនណានទទួលជោគជ័យក្នុងការហោះហើរជាលើកដំបូង

*យន្តហោះប្រភេទ DL-2L កំពុងតែត្រួតពិនិត្យមុនពេលហោះហើរ (រូបថតពី អនឡាញ)*

***ដោយ លី ស៊ីហ្ស៊ុន***

ពេលថ្មីៗនេះ យន្តហោះប្រភេទ DL-២L ដែលសិក្សាស្រាវជ្រាវ និងផលិតដោយក្រុមហ៊ុនបច្ចេកវិជ្ជាហារស្យេង ក្រុងមីឡីខេត្តយូនណានបានសាកល្បងហោះហើរដោយជោគជ័យជាលើកដំបូង ។ នេះជាយន្តហោះធុនស្រាល ទី១ ដែលផលិតដោយខេត្តយូនណាន ហើយបានបង្ហាញពីការរីកចម្រើនលើវិស័យផលិតកម្មអាកាសចរណ៍របស់ ខេត្តយូនណាន ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា យន្តហោះប្រភេទ DL-២L នេះជាយន្តហោះធុនស្រាលទី១ ដែលសិក្សាស្រាវជ្រាវ និងផលិតដោយសហគ្រាសឯកជននៅភូមិភាគនិរតីប្រទេសចិន ។ គួរបញ្ជាក់ថា យន្តហោះប្រភេទនេះផលិតដោយស្របតាមស្តង់ដារអាកាសចរណ៍ថ្មីរបស់ប្រទេសចិន ហើយកាន់កាប់កម្មសិទ្ធិបញ្ញាទាំងស្រុង ដោយសហគ្រាសចិន ។ យន្តហោះប្រភេទនេះធ្វើអំពីសម្ភារៈចម្រុះដែលអាចហោះហើរក្នុងល្បឿន២២០គីឡូម៉ែត្រក្នុងម៉ោង ។ យន្តហោះនេះអាចហោះហើរក្នុងលំហរអាកាស ដែលមានកម្ពស់ជាអតិបរមា ៤.៥០០ម៉ែត្រ និងហោះបានចម្ងាយ ១.២០០គីឡូម៉ែត្រ ។ ទម្ងន់សរុបជាអតិបរមាគឺ៦០០គីឡូក្រាម ។

យន្តហោះនេះអាចប្រើប្រាស់សម្រាប់បង្ហាត់អ្នកបើកយន្តហោះវាស់ស្ទង់ពីលើអាកាសបណ្តេញសត្វស្លាបជុំវិញព្រលានយន្តហោះយោមល្បាតការពារអគ្គិភ័យ និងវាស់ស្ទង់ដែនដីជាដើម ។ តាមការព្យាករណ៍យន្តហោះប្រភេទនេះនឹងត្រូវផ្សាយលក់តាមទីផ្សារក្នុងតម្លៃប្រហែល១,២ លានយ័ន ។

## គណៈរដ្ឋមន្ត្រីថៃផ្តល់ការអនុញ្ញាតឱ្យសាងសង់ខ្សែផ្លូវដែកបាងកក-គោរាជ

***ដោយ យ៉ាង ចូវ***

នៅថ្ងៃទី១១ ខែកក្កដា គណៈរដ្ឋមន្ត្រីថៃបានផ្តល់ការអនុញ្ញាតឱ្យសាងសង់ខ្សែផ្លូវដែកបាងកក-គោរាជ ដែលជាផ្នែកមួយនៃគម្រោងសហប្រតិបត្តិការផ្លូវដែកចិន-ថៃ ។ គម្រោងនេះនឹង បើកការដ្ឋានសាងសង់នៅខែកញ្ញាឆ្នាំនេះ ហើយមានរយៈពេលសាងសង់៤ ឆ្នាំ ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា ខ្សែផ្លូវដែកនេះមានប្រវែងសរុប២៥៣ គីឡូម៉ែត្រ ។ បន្ទាប់ពីបញ្ចប់ការសាងសង់ខ្សែផ្លូវដែកនេះ រថភ្លើងអាចធ្វើដំណើរក្នុងល្បឿន២៥០គីឡូម៉ែត្រក្នុងម៉ោងពីក្រុងបាងកកទៅខេត្តគោរាជ ដោយឆ្លងកាត់ព្រលានយន្តហោះបាងកក ។ តាមការព្យាករណ៍គម្រោងនេះនឹងចំណាយថវិកា១៧៩.៤០០លានបាត(ស្មើនឹង៣៥.៨០០លានយ័នប្រាក់ចិន)ដែលនឹងផ្តល់ដោយរដ្ឋាភិបាលថៃ។

តាមនីតិវិធីនៃប្រទេសថៃគម្រោងនេះនឹងត្រូវប្រគល់ជូនសភានីតិបញ្ញត្តិប្រទេសថៃ ដើម្បីពិនិត្យសម្រេច ។ បើសិនជាសភានីតិបញ្ញត្តិប្រទេសថៃបានឯកភាពវិស្វកម្មសាងសង់ផ្លូវដែកនេះ នឹងត្រូវបែងចែកជាកំណាត់ច្រើន ដើម្បីរៀបចំការដេញថ្លៃ ។ គួរបញ្ជាក់ថា ក្រុមហ៊ុនថៃ នឹងទទួលខុសត្រូវចំពោះការសាងសង់ផ្លូវដែកនេះ ចំណែកភាគីចិនផ្តល់ការគាំទ្រផ្នែកបច្ចេកទេសប្រព័ន្ធភ្លើងសញ្ញា និងការបណ្តុះបណ្តាលបច្ចេកទេស ។

បន្ទាប់ពីបញ្ចប់កិច្ចប្រជុំគណៈរដ្ឋមន្ត្រីខាងលើលោក ប្រាយុទ្ធ ចាន់អូចា នាយករដ្ឋមន្ត្រីថៃ បានប្រកាសជាសាធារណៈថា ខ្សែផ្លូវដែកបាងកក-គោរាជនេះ ជាគម្រោងដំណាក់កាលទី១ នៃគម្រោងសហប្រតិបត្តិការផ្លូវដែកចិន-ថៃ ។ បន្ទាប់ពីនោះរដ្ឋាភិបាលថៃនឹងបន្តជំរុញការអនុវត្តគម្រោងដំណាក់កាលទី២ គឺខ្សែផ្លូវដែកគោ រាជ-ហ្ងុងខាយ ។ តាមការឧទ្ទេសនាមបានឱ្យដឹងថា គម្រោងសាងសង់ខ្សែផ្លូវដែកដំណាក់កាលទី២នេះអាចតភ្ជាប់ទៅនឹងខ្សែរថភ្លើងចិន-ឡាវ (គុនមីង-វ៉ៀងចន្ទន៍) ដែលកំពុងតែដំណើរការ សាងសង់នាពេលបច្ចុប្បន្ន ហើយនឹងអាចតភ្ជាប់ប្រទេសថៃ ចិន ឡាវ ម៉ាឡេស៊ី និងសិង្ហបុរី ។